ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៣៦៦...សហវ....ប្រក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការបំពេញចំណូលភាគពួកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦៥អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង ក្នុងគោលដៅធានាបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ការកំណត់ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង

**ប្រការ៣ .-**

ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៈ ត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូប្រចាំគ្រាក្នុងអំឡុងពេលនៃការកាន់កាប់អាជ្ញាបណ្ណ អនុលោមតាមមាត្រា៨២ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។ អត្រានៃចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូត្រូវបានកំណត់ដូចខាងក្រោម÷

ក. កាស៊ីណូដែលស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៈចំនួន ៤ (បួន) ភាគរយ ចំពោះភ្ញៀវល្បែងពិសេស និងចំនួន ៧ (ប្រាំពីរ) ភាគរយ ចំពោះភ្ញៀវល្បែងធម្មតា។

ខ. កាស៊ីណូដែលមិនស្ថិតនៅក្នុងមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណៈចំនួន ៧ (ប្រាំពីរ) ភាគរយ។

មូលដ្ឋាននៃការគណនាចំណូលកាតព្វកិច្ចពីល្បែង គឺចំណូលសរុបពីល្បែង។ ចំណូលសរុបពីល្បែងត្រូវបានគណនាដូចខាងក្រោម÷

ក. ចំណូលដុលដែលទទួលបានឬត្រូវទទួលបានពីល្បែងគ្រប់ប្រភេទ ដែលមានដំណើរការនៅក្នុងកាស៊ីណូ

ខ. ដកចេញនូវប្រាក់ឈ្នះទាំងឡាយរបស់ភ្ញៀវល្បែង។

របៀបនៃការគណនាចំណូលសរុបពីល្បែងកាស៊ីណូ មានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៤ .-**

ប្រតិបត្តិករល្បែងផ្សងសំណាង ត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងប្រចាំគ្រាក្នុងអំឡុងពេលនៃការកាន់កាប់អាជ្ញាបណ្ណ អនុលោមតាមមាត្រា៨៣ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។ អត្រានៃចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាង ត្រូវកំណត់ដូចខាងក្រោម÷

- ឆ្នាំទី១ ដល់ឆ្នាំទី៥ ចំនួន ១០ (ដប់) ភាគរយនៃចំណូលដុល

- ឆ្នាំទី៦ ដល់ឆ្នាំទី១០ ចំនួន ១២ (ដប់ពីរ) ភាគរយនៃចំណូលដុល
- ឆ្នាំទី១១ ដល់ឆ្នាំទី១៥ ចំនួន ១៣ (ដប់បី) ភាគរយនៃចំណូលដុល
- ឆ្នាំទី១៦ ដល់ឆ្នាំទី២៥ ចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃចំណូលដុល។

ប្រតិបត្តិករល្បែងផ្សងសំណាងត្រូវបំពេញចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាងទាបបំផុតត្រឹមចំនួនអប្បបរមា ១០.០០០.០០០ (ដប់លាន) រៀល ក្នុងមួយខែ និងត្រូវបង់មូលនិធិសង្គមរបស់ **គ.ល.ក.** ចំនួន ២ (ពីរ) ភាគរយនៃចំណូលដុលបន្ថែមលើអត្រាចំណូលកាតព្វកិច្ចពីល្បែងផ្សងសំណាង ដែលបានកំណត់ខាងលើ។

## ជំពូកទី៣

## លក្ខខណ្ឌ និងនីតិវិធីនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង

**ប្រការ៥ .-**

ប្រតិបត្តិករកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាងត្រូវមាននិងរក្សាកិច្ចបញ្ជិកាគណនេយ្យ ដោយអនុលោមតាមមាត្រា៥៥ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

**ប្រការ៦ .-**

ប្រតិបត្តិករកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាងត្រូវធានាឱ្យមានសវនកម្មឯករាជ្យប្រចាំឆ្នាំលើរបាយការណ៍ហិរញ្ញវត្ថុ និងលើអនុលោមភាពនៃដំណើរការត្រួតពិនិត្យផ្ទៃក្នុងស្របតាមស្តង់ដាអប្បបរមានៃការត្រួតពិនិត្យផ្ទៃក្នុងដែលកំណត់ដោយ **គ.ល.ក.** ដោយអនុលោមតាមមាត្រា៥៦ នៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម។

**ប្រការ៧ .-**

ការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង ត្រូវធ្វើឡើងដោយស្វ័យប្រកាសរបស់ប្រតិបត្តិករជារៀងរាល់ខែ យ៉ាងយូរត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ តាមទម្រង់លិខិតប្រកាសចំណូលកាតព្វកិច្ចពីល្បែងដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.** និងជាកម្មវត្ថុនៃការធ្វើសវនកម្ម។

ចំណូលកាតព្វកិច្ចពីល្បែងត្រូវបង់ចូលក្នុងគណនីថវិការដ្ឋលេខ ០០០០០០០០១១១១សម្រាប់រូបិយប័ណ្ណជាតិ ឬគណនីលេខ ០០០០០០០១៣៥៣៥សម្រាប់រូបិយប័ណ្ណបរទេស នៅធនាគារជាតិនៃកម្ពុជា។

ចំពោះការបង់មូលនិធិសង្គមរបស់ **គ.ល.ក.** ប្រតិបត្តិករល្បែងផ្សងសំណាងត្រូវបង់ចូលទៅក្នុងគណនីថវិការបស់ **គ.ល.ក.** ទៅតាមទម្រង់ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ **គ.ល.ក.**។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

**ប្រការ៨ .-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀត ប្រតិបត្តិករកាស៊ីណូ និង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ និងប្រតិបត្តិករល្បែងផ្សងសំណាងដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលរងពិន័យអន្តរការណ៍ ដោយអនុលោមតាមអនុក្រឹត្យស្តីពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

# ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ៩ ._**

ចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាងដូចមានចែងក្នុងប្រការ៣ និងប្រការ៤ នៃប្រកាសនេះ ត្រូវអនុវត្តចាប់ពីឆ្នាំសារពើពន្ធ ២០២១ នេះតទៅ។

ប្រតិបត្តិករល្បែងកាស៊ីណូ និងប្រតិបត្តិករល្បែងផ្សងសំណាងដែលបានបំពេញចំណូលកាតព្វកិច្ចពីល្បែងមុនប្រកាសនេះចូលជាធរមាន ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះចាប់ពីខែមករា ឆ្នាំ២០២២ តទៅ។

# ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ១០ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១._**

អគ្គលេខាធិការ អគ្គលេខាធិការរង គ.ល.ក. ប្រធាននាយកដ្ឋានត្រួតពិនិត្យ និងគ្រប់គ្រងចំណូលប្រតិបត្តិករកាស៊ីណូ កម្មសិទ្ធិករកាស៊ីណូ កម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរណ៍ ប្រតិបត្តិករល្បែងផ្សងសំណាង និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាសភាពនៃ គ.ល.ក.

“ដើម្បីជូនជ្រាប”

- ដូចប្រការ១១ “ដើម្បីអនុវត្ត”
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃប្រកាសលេខ ៦២៤ សហវ.ប្រក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២១**

**ស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការបំពេញចំណូលកាតព្វកិច្ចពីល្បែងកាស៊ីណូ និងល្បែងផ្សងសំណាង**

## របៀបនៃការគណនាចំណូលសរុបពីល្បែងកាស៊ីណូ

មូលដ្ឋាននៃការគណនាចំណូលកាតព្វកិច្ចពីល្បែង គឺចំណូលសរុបពីល្បែង។ ចំណូលសរុបពីល្បែងត្រូវបានគណនាដូចខាងក្រោម÷

ក. ចំណូលដុលដែលទទួលបានឬត្រូវទទួលបានពីល្បែងគ្រប់ប្រភេទ ដែលមានដំណើរការនៅក្នុងកាស៊ីណូ

ខ. ដកចេញនូវប្រាក់ឈ្នះទាំងឡាយរបស់ភ្ញៀវល្បែង។

ការគណនាចំណូលសរុបពីល្បែងកាស៊ីណូត្រូវអនុវត្តតាមវិធានដូចខាងក្រោម÷

### I. របៀបគណនាចំណូលសរុបពីតុល្បែង

ចំណូលសរុបពីតុល្បែងស្មើនឹង សារពើភ័ណ្ឌតុចុងគ្រា **បូកនឹង** ឥណទាន (Credits) **បូកនឹង** ទម្លាក់ (Drop) **រួចដកនឹង** សារពើភ័ណ្ឌតុដើមគ្រា ហើយដកនឹងហ្វិល (Fills)។

<u>សម្គាល់÷</u>

១. យោងតាមសន្ទានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម តុល្បែង សំដៅដល់តុសម្រាប់បម្រើដល់ការលេងល្បែងនៅក្នុងកាស៊ីណូ រួមមាន÷ តុបាការ៉ាត ប្លេកជេក ផូកឃើ រ៉ូឡែត និងតុល្បែងពាណិជ្ជកម្មដទៃទៀត ដែលអនុញ្ញាតដោយ **គ.ល.ក.**។

២. ទម្លាក់ (drop) គឺជាចំនួនសរុបនៃទឹកប្រាក់, កាក់ល្បែង (chips), ថូខិន (tokens) និងឥណទានទាំងឡាយដែលនៅក្នុងប្រអប់ទម្លាក់ (drop box)។

៣. ហ្វិល (fills) គឺជាកាក់ល្បែងដែលបានបញ្ជូនមកតុល្បែងពីខេច (cage)។

៤. ឥណទាន (credits) អាចជាទឹកប្រាក់ ជាកាក់ល្បែង ឬជាថូខិន ដែលត្រូវបានដកចេញពីតុល្បែងហើយបញ្ជូនទៅខេច (cage) វិញ។

៥. សារពើភ័ណ្ឌតុដើមគ្រា (opening table inventory) គឺជាចំនួនកាក់ល្បែងដែលនៅក្នុងថាស (tray) ពេលដែលវេនលេងចាប់ផ្តើម។

៦. សារពើភ័ណ្ឌតុចុងគ្រា (closing table inventory) គឺជាចំនួនកាក់ល្បែងដែលនៅក្នុងថាស (tray) ពេលដែលវេនលេងត្រូវបានបញ្ចប់។

ចំណូលសរុបពីតុល្បែងទាំងអស់ត្រូវគណនាតាមរូបមន្តដូចខាងក្រោម÷

| | | |
|---|---|---|
| | **សារពើភ័ណ្ឌតុចុងគ្រា** | + |
| | ឥណទាន (Credits) | + |
| | ទម្លាក់ (Drop) | + |
| | សារពើភ័ណ្ឌតុដើមគ្រា | - |
| | ហ្វិល (Fills) | - |
| = | **ចំណូលសរុបពីតុល្បែង** | + or - |

**ឧទាហរណ៍ ១៖**

| | | |
|---|---|---|
| ទឹកប្រាក់នៅក្នុងប្រអប់ទម្លាក់ (drop box) | $ 6,000 | |
| ឥណទាន (credit issued and outstanding) | $ 3,000 | |
| *សរុបក្នុងប្រអប់ទម្លាក់* | | $ 9,000 |
| សារពើភ័ណ្ឌតុដើមគ្រា (opening table inventory) | $ 14,000 | |
| ការផ្ទេរកាក់ល្បែង (Chips transfer) | | |
| ហ្វិល (Fills) | $ 5,000 | |
| ឥណទាន (Credits) | $ 1,000 | |
| សារពើភ័ណ្ឌតុចុងគ្រា (closing table inventory) | $ 11,000 | |
| **ចំណូលសរុបពីតុល្បែង (GGR)** | | $ 2,000 |

| | | | |
|---|---|---|---|
| | សារពើភ័ណ្ឌតុចុងគ្រា | + | 11,000 |
| | ឥណទាន (Credits) | + | 1,000 |
| | ទម្លាក់ (Drop) | + | 9,000 |
| | សារពើភ័ណ្ឌតុដើមគ្រា | - | (14,000) |
| | ហ្វិល (Fills) | - | (5,000) |
| = | **ចំណូលសរុបពីតុល្បែង** | + or - | 2,000 |

## II. របៀបគណនាចំណូលសរុបពីម៉ាស៊ីនល្បែង

ចំណូលសរុបពីម៉ាស៊ីនល្បែង **ស្មើនឹង** ទម្លាក់ (Drop) **ដកនឹង** ការកាត់បន្ថយ (Deductions and timing issues)។

**សម្គាល់÷**

១. ម៉ាស៊ីនល្បែងសំដៅដល់ឧបករណ៍ ទោះមានលក្ខណៈជាមេកានិក ឬអេឡិចត្រូនិកទាំងស្រុង ឬមួយផ្នែកក្តី ដែលត្រូវបានផលិតឡើង ដើម្បីប្រើប្រាស់សម្រាប់បម្រើដល់ការលេងល្បែងផ្សងសំណាងសុទ្ធសាធ ឬ ល្បែងផ្សងសំណាងរួមជាមួយនឹងជំនាញនិងម៉ាស៊ីនដទៃទៀត រួមមាន ស្លុតម៉ាស៊ីន រ៉ូឡែតម៉ាស៊ីន ជាដើម។

២. ទម្លាក់ (drop) គឺទឹកប្រាក់ក្នុងស្លុតម៉ាស៊ីនដែលបានមកពីគ្រប់ប្រភព

- ហ្វិល (Fills) គឺជាកាក់ល្បែងដែលត្រូវបំពេញក្នុងម៉ាស៊ីនពីខេច (cage)
- លុយក្នុងម៉ាស៊ីនដែលបានមកពីអតិថិជន; អាចជាទឹកប្រាក់បានមកពី ប៊ីលវ៉ាលីដេតទ័រ (bill validator), ធីកឃីតវូចឈ័រ (ticket voucher), កាក់ល្បែងឬ ប្រាក់ផ្ទេរតាមអេឡិចត្រូនិក

៣. ការកាត់បន្ថយ (Deductions and timing issues)

- ហ្វិល (Fills) គឺជាទឹកប្រាក់ស្តុកទុកស្រាប់ក្នុងម៉ាស៊ីនដែលមិនមកពីអតិថិជន
- សំបុត្រចេញ, Jackpots បង់ដោយដៃ, ការផ្ទេរពីគណនីភ្នាល់ទៅអតិថិជន
- ចំនួនផ្លាស់ប្តូរសុទ្ធនៃ hopper balance (ចំនួនឈ្នះសុទ្ធឬចាញ់សុទ្ធនៃកាក់)។

**ឧទាហរណ៍ ២÷**

| | | |
|---|---|---|
| **ទម្លាក់ (drop):** | | |
| ទឹកប្រាក់និងសំបុត្រដកចេញពី Currency acceptors | $ 2,000 | |
| កាក់ល្បែងដកចេញពីធុងទម្លាក់ (Drop bucket) | $ 2,000 | |
| លុយបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិចពីគណនីភ្នាល់មកម៉ាស៊ីនល្បែង (Electronic money transfers from wagering account to the machine) | $ 1,000 | |
| **ទម្លាក់សរុប** | | $ 5,000 |
| **ការកាត់បន្ថយ (Deductions and timing issues):** | | |
| ប័ណ្ណដែលចេញដោយម៉ាស៊ីន (Tickets issued by machine) | $(1,000) | |
| ហ្វិល (Fills) | $(1,000) | |
| រង្វាន់ជេកផត (Hand Paid Jackpots) | $(1,000) | |
| លុយបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិចពីម៉ាស៊ីនល្បែងទៅគណនីភ្នាល់ | $(1,000) | |
| ការផ្លាស់ប្តូរនៃ Hopper balance | $(200) | |
| **សរុបការកាត់បន្ថយ** | | $(4,200) |
| **ចំណូលសរុបពីម៉ាស៊ីនល្បែង** | | $ 800 |

**បញ្ជាក់÷**

រាល់ការចំណាយដែលត្រូវបានចាត់ទុកថាជាចំណាយធ្វើឡើងក្នុងគោលបំណង ដើម្បីទាក់ទាញភ្ញៀវមកលេងល្បែង មិនត្រូវបានអនុញ្ញាតអោយយកមកទូទាត់ក្នុងការគណនាចំណូលសរុបពីតុល្បែងឡើយ។ ការចំណាយនេះរួមមាន រង្វាន់ (prizes), ប័ណ្ណ (tickets), អត្ថប្រយោជន៍ (benefits) ផ្សេងៗទៀត ដែលអាចទូទាត់សងជាប្រាក់ឬទំនិញ (merchandise) ឬប្រាក់ឧបត្ថម្ភផ្សព្វផ្សាយផ្សេងៗ (other promotional allowance)។

ការគណនាចំណូលសរុបមិនត្រូវបានរាប់បញ្ចូលនូវ (gross revenue does not include)÷

១. សាច់ប្រាក់, កាក់ល្បែង, ថូខិនណាដែលថតចម្លង ឬក្លែងបន្លំ (counterfeit facsimiles of money, chips, tokens, wagering instruments or wagering credits)។

២. កាក់ល្បែងពីប្រទេសផ្សេងដែលទទួលបានក្នុងម៉ាស៊ីនល្បែង (Coins of other countries which are received in gaming devices)។

៣. កាក់ល្បែង ឬថូកខិន ដែលប្រតិបត្តិករទទួលបានពីភ្ញៀវ ប៉ុន្តែមិនមានភស្តុតាងបង្ហាញថា ភ្ញៀវនោះបានទិញកាក់ល្បែង ឬថូកខិនដោយសាច់ប្រាក់របស់ខ្លួនទេ (Any portion of the face value of any chip, token or other representative of value won by a licensee from a patron for which the licensee can demonstrate that it or its affiliate has not received cash)។

៤. សាច់ប្រាក់ដែលបានមកពីអំពើខុសច្បាប់ដោយមានការក្លែងបន្លំចំពោះប្រតិបត្តិករ ហើយប្រតិបត្តិករមិនធានាសងវិញ (cash taken in fraudulent acts perpetrated against a licensee for which the licensee is not reimbursed)។

៥. សាច់ប្រាក់ដែលបានមកពីការបង់កម្រៃចូលក្នុងកម្មវិធីប្រកួតប្រជែងណាមួយ ដែលភ្ញៀវប្រកួតសម្រាប់ឈ្នះរង្វាន់ (cash received as entry fees for contests or tournaments in which patrons compete for prizes)។

៦. កម្រៃពីតុបាការ៉ាតដែលមិនប្រមូល (uncollected baccarat commissions)។